# ការកសាងប្រទេសកម្ពុជាអោយឆ្លងផុតវិបត្តិ — ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំណើននៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ: ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល ដើម្បីជួយទ្រទ្រង់មូលដ្ឋានផលិតកម្មកម្ពុជា

*អត្ថបទនេះ សង្ខេបបទបង្ហាញរបស់ ឯកឧត្តម បណ្ឌិត ទី នរិន្ទ និង លោក Stephen Higgins[១] នៅវគ្គទី ៣ខ (១) នៃសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

ការជំរុញឧស្សាហូបនីយកម្ម គឺជាយុទ្ធសាស្ត្រធ្លាប់អនុវត្តបានសក្តិសិទ្ធិហើយ ដើម្បីជួយសំរួលដល់វឌ្ឍនភាពជាតិ និងការអភិវឌ្ឍ ។ វាជាមាគ៌ាដែលប្រទេសមានសេដ្ឋកិច្ចកំពុងរីកចំរើនជាច្រើន ធ្លាប់ប្រើប្រាស់បានជោគជ័យ ដូចជាប្រទេសថៃ ជាដើម ។ ថៃបានចាប់ផ្ដើមធ្វើទំនើបភាវូបនីយកម្មតាំងពីចុងទសវត្សរ៍១៩៥០ ដែលបានជួយបង្កើនចំណូលក្នុងមនុស្សម្នាក់ពី ១០០ដុល្លារ រហូតដល់ប្រហែល ៣០០០ដុល្លារនាពេលបច្ចុប្បន្ន ។ កត្តាស្នូលនៃដំណើរការនេះ គឺ ការពង្រីកកម្មន្តសាលកម្ម ដែលធ្វើឱ្យចំណែកនៃផ្នែកនេះនៅក្នុង ផសស កើនឡើងមួយជាបី ។ ដូចគ្នានឹងប្រទេសផ្សេងទៀតដែរ កម្មន្តសាលកម្មនៅថៃផ្ដើមចេញពីឧស្សាហកម្មអតិពលកម្ម ហើយបន្ទាប់មកបានឆ្លងផុតដំណាក់កាលនេះ ដោយការជំរុញ និងទាក់ទាញកម្មន្តសាលកម្មធុនស្រាល ។ កត្តាដែលជួយបង្កើនល្បឿននៃការផ្លាស់ប្ដូរនេះ គឺកំណើនប្រាក់ចំណូល និងតំរូវការរបស់អ្នកប្រើប្រាស់ ។

ផ្អែកលើបទពិសោធន៍នៅប្រទេសដទៃទៀត ឧស្សាហូបនីយកម្ម គឺជាគន្លឹះនៃការផ្លាស់ប្ដូរសេដ្ឋកិច្ចកម្ពុជា ។ វិស័យឧស្សាហកម្ម បានជួយទ្រទ្រង់ខ្លាំងដល់កំណើនល្អវិសេសរបស់កម្ពុជា ហើយចំណែកនៃវិស័យនេះ ក្នុង ផសស កើនឡើងស្ទើរមួយជាពីរ ក្នុងទសវត្សរ៍កន្លងទៅ ។ ប៉ុន្តែចំណែកនេះមានកំរិតទាបនៅឡើយ បើធៀបនឹងថៃ ឬ វៀតណាម ( ក្រាហ្វិក ១) ។

នៅកម្ពុជា សកម្មភាពឈានមុខគេក្នុងការពង្រីកវិស័យឧស្សាហកម្ម គឺផ្នែកកម្មន្តសាលកម្ម និងសំណង់ ហើយកំណើនកម្មន្តសាលកម្ម គឺផ្អែកលើសកម្មភាពកាត់ដេរ ។ សំលៀកបំពាក់តំណាងឱ្យប្រហែលពាក់កណ្ដាល នៃផលិតផលឧស្សាហកម្មកម្ពុជានាពេលបច្ចុប្បន្ន និងជាទំនិញនាំចេញចំបងគេ ។ សមត្ថភាពភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរ ត្រូវបានកែលំអដោយសារកំណើនផលិតភាពពលករក្នុងវិស័យនេះដល់កំរិតមួយស្មើគ្នានឹងប្រទេសវៀតណាម ។ វិស័យកាត់ដេរផ្ដល់ការងារបានតែ ១៣% ប៉ុណ្ណោះដល់កម្លាំងពលកម្មក្នុងស្រុក ដែលជាតួលេខដ៏ទាប បើធៀបនឹងអត្រា ៥៩% នៃវិស័យកសិកម្ម ( តួលេខសំរាប់ឆ្នាំ២០០៧) ។ ចំពោះសកម្មភាពផលិតកម្មផ្សេងៗទៀតនៅកម្ពុជា វានៅតូចនៅឡើយ បើធៀបនឹងវិស័យកាត់ដេរ ។ ឧទាហរណ៍ដូចជា ផលិតកម្មម្ហូបអាហារ តំណាងឱ្យមិនដល់ ១០% នៃផលិតផលឧស្សាហកម្មសរុបទេ ។

ក្រាហ្វិក ១: ចំណែកឧស្សាហកម្មក្នុង ផសស




*ប្រភព: ធនាគារពិភពលោក Breisinger និង Diao*

ឧបសគ្គធំបំផុតដល់ការពង្រីកកម្មន្តសាលកម្មថែមទៀត គឺ ហេដ្ឋារចនាសម្ព័ន្ធមិនទាន់អភិវឌ្ឍបានគ្រប់គ្រាន់ ជាពិសេស បណ្ដាញផ្លូវថ្នល់ និងការផ្គត់ផ្គង់អគ្គិសនី ។

គេប៉ាន់ស្មានថា សហគ្រាសនានានៅកម្ពុជាផលិតបាន ៣៦% នៃតំរូវការអគ្គិសនីរបស់ខ្លួនដោយប្រើម៉ាស៊ីនភ្លើង ។គេប៉ាន់ស្មានទៀតថា ម៉ាស៊ូតតំណាងឱ្យជាង ២០% នៃចំណាយប្រតិបត្តិការរបស់ សណ្ឋាគារមួយចំនួន ។ តួលេខទាំងនេះ គូសបញ្ជាក់ពី បញ្ហាចោទធ្ងន់ធ្ងរក្នុងការផ្គត់ផ្គង់អគ្គិសនី ( ប្រអប់ ១) ។

ស្ថានភាពខ្សត់ខ្សោយនៃការដឹកជញ្ជូន អាចមើលឃើញយ៉ាងច្បាស់តាមរយៈចំណាយខ្ពស់ ក្នុងការដឹកជញ្ជូនផលិតផលកសិកម្ម ។ របាយការណ៍ថ្មីៗមួយរបស់ធនាគារពិភពលោក បានលើកថា នៅកម្ពុជា ការដឹកជញ្ជូនផលិតផលកសិកម្ម ក្នុងមួយតោនក្នុងចំងាយ ១០០គីឡូម៉ែត្រ ត្រូវចំណាយអស់ ១៥ដុល្លារ ដែលខ្ពស់ជាងវៀតណាម ( ៧,៥ដុល្លារ) និង ថៃ ( ៤ដុល្លារ) ។ ស្ថានភាពនេះហាក់ដូចជាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ពីព្រោះនៅកម្ពុជា ផ្លូវចាក់កៅស៊ូ មានត្រឹម ៦,៣% ប៉ុណ្ណោះ ធៀបនឹង ២៥% នៅវៀតណាម និង ៩៨% នៅថៃ ( ក្រាហ្វិក ៣) ។

---

១ ឯកឧត្តម បណ្ឌិត ទី នរិន្ទ ជាប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ។ លោក Stephen Higgins ជាអគ្គនាយក នៃធនាគារ ANZ Royal ។

រដ្ឋាភិបាលបានដឹងច្បាស់ ពីតំរូវការចាំបាច់នៃការកសាងហេដ្ឋារចនាសម្ព័ន្ធ ។ ផែនការទ្រង់ទ្រាយធំ សំរាប់កែលំអទាំងការផ្គត់ផ្គង់អគ្គិសនី និងបណ្ដាញដឹកជញ្ជូន កំពុងតែអនុវត្តហើយ ។ គម្រោងដ៏លេចធ្លោមួយ គឺ "ប្រព័ន្ធអភិវឌ្ឍន៍អគ្គិសនីកម្ពុជា ឆ្នាំ២០១៣-២០១៨" ដែលសំដៅអភិវឌ្ឍប្រព័ន្ធចែកចាយអគ្គិសនី ។ ផ្អែកតាមផែនការនេះ បណ្ដាញអគ្គិសនីថ្នាក់ជាតិដែលមានកំរិតវ៉ុលខ្ពស់ នឹងត្រូវបង្កើតឡើង ដោយផ្ដើមចេញពី រាជធានីភ្នំពេញ និងសំដៅតភ្ជាប់ទៅទីផ្សារទាំងអស់ ។ បណ្ដាញនេះក៏នឹងត្រូវភ្ជាប់ជាមួយទំនប់វារីអគ្គិសនី ដែលមានស្រាប់ និងដែលត្រូវកសាងទៅអនាគតផងដែរ ។ ក្នុងដំណាក់កាលបន្ទាប់ គម្រោងនេះផ្ដោតលើការនាំចូលអគ្គិសនីពីវៀតណាម និងថៃ ។ ក្នុងពេលសព្វថ្ងៃ មានគម្រោងវារីអគ្គិសនីចំនួន ៣ ដែលកំពុងសាងសង់ ។

ប្រព័ន្ធផ្លូវជាតិបានកែលំអជិតរួចរាល់ហើយ ចំណែកឯប្រព័ន្ធផ្លូវខេត្តកំពុងបន្តចាក់កៅស៊ូ ។

នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ។ ភាពជាដៃគូរវាងរដ្ឋ-ឯកជន ត្រូវបង្កើនឡើងទាំងលើចំនួន និងវិសាលភាព ដើម្បីញ៉ាំងឱ្យមានការចែករំលែកបានកាន់តែច្រើននូវបន្ទុកចំណាយ ។ ដោយសារធនធានមានកំណត់ រដ្ឋាភិបាលត្រូវបន្តចរចាសុំការគាំទ្រកាន់តែច្រើនពីម្ចាស់ជំនួយ សំរាប់អគ្គិសនីកម្ពុជា ។ បន្ថែមលើនេះទៀត ប្រព័ន្ធអភិវឌ្ឍន៍អគ្គិសនីកម្ពុជា ដែលជាផែនការដ៏ល្អមួយ ក៏ត្រូវសម្រេចឱ្យបានដែរ ដើម្បីបង្កើនស្ថិរភាព និងកែលំអការផ្គត់ផ្គង់ ក៏ដូចជា បញ្ចុះតំលៃអគ្គិសនី ។ គេរំពឹងថា នៅពីរបីឆ្នាំខាងមុខ បណ្ដាញអគ្គិសនីថ្នាក់ជាតិ នឹងត្រូវតភ្ជាប់ទៅនឹងស្ថានីយវារីអគ្គិសនីទាំងអស់ដែលបានអភិវឌ្ឍរួចហើយ ។ សមត្ថភាពផ្គត់ផ្គង់អគ្គិសនី ក៏រំពឹងថានឹងកើនឡើងគួរឱ្យកត់សម្គាល់ នៅតាមតំបន់ដែលទទួលការផ្គត់ផ្គង់ពីអនុស្ថានីយនៃបណ្ដាញអគ្គិសនី ។ ឧស្សាហកម្មសំខាន់ៗ និងតំបន់សេដ្ឋកិច្ចពិសេសៗ ក្នុងរង្វង់ចំងាយ ១០គីឡូម៉ែត្រពីអនុស្ថានីយ អាចទទួលបានអគ្គិសនីដែលផ្គត់ផ្គង់តាមខ្សែកាបតចូលផ្ទាល់និងមានថ្លៃទាប ។ឧស្សាហកម្មដែលផលិតអគ្គិសនីខ្លួនឯង ដោយប្រើម៉ាស៊ីនភ្លើងចាក់ម៉ាស៊ូត ក៏អាចតភ្ជាប់នឹងបណ្ដាញផ្គត់ផ្គង់អគ្គិសនីមានតំលៃថោកដែរ ។ វិធានការផ្សេងទៀតដើម្បីកាត់បន្ថយថ្លៃអគ្គិសនី មានដូចជា ការអភិវឌ្ឍប្រភពថាមពលផ្សេងៗដែលមានតម្លៃថោក និងការបង្កើនប្រសិទ្ធភាពប្រតិបត្តិការដែលតម្រូវឱ្យ

### ប្រអប់ ១: ការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជា — បញ្ហាចំបងៗ

**បញ្ហាទី ១: ការផ្គត់ផ្គង់មិនគ្រប់គ្រាន់**

ការផ្គត់ផ្គង់ នៅខ្វះខាតខ្លាំងណាស់ ។ គេប៉ាន់ស្មានថា តំរូវការអគ្គិសនីបានកើនឡើងពី ២០% ទៅ ២៦% ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយសមត្ថភាពផលិតអគ្គិសនីនៅពេលបច្ចុប្បន្នមិនអាចឆ្លើយតបទៅនឹងតំរូវការបានទេ ។ ភាពពឹងផ្អែកយ៉ាងខ្លាំងលើឥន្ធនៈនាំចូលសំរាប់ការផលិតថាមពលក៏នាំឱ្យការផ្គត់ផ្គង់មានលក្ខណៈមិនប្រាកដប្រជា និងបន្ទុកចំណាយខ្ពស់ទៀតផង ។ ប្រទេសកម្ពុជាមានសក្ដានុពលខាងវារីអគ្គិសនី ប៉ុន្តែសក្ដានុពលនេះមិនអាចជឿទុកចិត្តទាំងស្រុងបានទេ ដោយសារភ្លៀងមិនទៀងទាត់ និងទឹកមានតិចនៅរដូវប្រាំង ហើយប្រទេសកម្ពុជាក៏ខ្វះខាតប្រភពថាមពលដទៃទៀតដូចជា ធ្យូងថ្ម និងឧស្ម័ន ជាដើម ។

**បញ្ហាទី ២: ភាពមិនអាចបានប្រើប្រាស់ និងភាពមិនអាចជឿទុកចិត្តបាននៃការផ្គត់ផ្គង់**

បញ្ហានេះ កើតឡើងដោយសារប្រព័ន្ធចែកចាយ និងបញ្ជូនអគ្គិសនី មានលក្ខណៈអន់ខ្សោយ ។ ការកែលំអ និងថែទាំប្រព័ន្ធទាំងនេះ ត្រូវធ្វើឡើងជាចាំបាច់ ដើម្បីធានាថា អគ្គិសនីបានទៅដល់កន្លែងប្រើប្រាស់ ហើយការផ្គត់ផ្គង់មានស្ថិរភាព ។ ទោះជាយ៉ាងនេះក្ដី ដើម្បីសំរេចគោលបំណងនេះបាន ត្រូវមានហិរញ្ញប្បទានយ៉ាងច្រើន ។

**បញ្ហាទី ៣: ចំណាយខ្ពស់**

ឧបសគ្គចំបងមួយចំពោះកំណើន គឺ តំលៃអគ្គិសនីខ្ពស់ពេក ( ក្រាហ្វិក ២) ។ ផ្អែកតាមធនាគារពិភពលោក នៅកម្ពុជា តំលៃអគ្គិសនីមានកំរិតពី ០,១៨ដុល្លារ នៅតំបន់ទីប្រជុំជន និង ០,៣០-០,៩០ដុល្លារ នៅជនបទ ។ តំលៃនេះខ្ពស់ណាស់ បើធៀបនឹងប្រទេសជិតខាង ដែលសុទ្ធតែមានតំលៃទាបជាង ០,១០ដុល្លារ ។ ក្រៅពីចំណាយខ្ពស់លើធាតុចូល និងការផលិតថាមពលមានលក្ខណៈដាច់ដោយដុំ កត្តាបង្កើនតំលៃអគ្គិសនីមួយទៀត គឺ កង្វះប្រសិទ្ធភាពនៃប្រតិបត្តិការនាំឱ្យមានការបាត់បង់អគ្គិសនីយ៉ាងច្រើននៅពេលបញ្ជូន និងចែកចាយ ។ គេប៉ាន់ស្មានថា ពីឆ្នាំ ១៩៩៨ ដល់ ២០០៨ អគ្គិសនីប្រហែល ១០,៧% បានបាត់បង់ ហើយការបាត់បង់នៅឆ្នាំមុនៗនោះទៀត មានរហូតដល់ ២៨-៣០% ។

**បញ្ហាទី ៤: កង្វះហិរញ្ញប្បទាន**

ត្រូវមានវិនិយោគច្រើនណាស់ ដើម្បីផ្ដល់ហិរញ្ញប្បទានដល់គម្រោងខ្នាតធំៗ ដើម្បីដោះស្រាយបញ្ហាដូចខាងលើ ។ នាពេលបច្ចុប្បន្ន រដ្ឋាភិបាលមិនមានសមត្ថភាពខាងហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីធ្វើវិនិយោគទេ ដូច្នេះត្រូវមានកិច្ចសហប្រតិបត្តិកាន់តែខ្លាំងក្លាជាមួយដៃគូអភិវឌ្ឍន៍នានា ។

*ប្រភព : ធនាគារពិភពលោក ការរក្សាកំណើនលឿន នៅក្នុងបរិយាកាសដ៏លំបាក ( ឯកសារជំនួយស្មារតីស្ដីពី សេដ្ឋកិច្ចកម្ពុជា) ២០០៩*

ក្រាហ្វិក ២: តំលៃអគ្គិសនីក្នុងមួយគីឡូវ៉ាត់ម៉ោង (គិតជាសេន)




ក្រាហ្វិក ៣: ភាគរយនៃផ្លូវចាក់កៅស៊ូ




ដោះស្រាយ បញ្ហាពិបាកៗមួយចំនួនទាក់ទងនឹងអភិបាលកិច្ច សេរីភាវូបនីយកម្មទីផ្សារ ការប្រកួតប្រជែងដោយយុត្តិធម៌ និងការកសាងបទបញ្ញត្តិគ្រប់គ្រងដោយឯករាជ្យ ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជួយបង្កើនសមត្ថភាពរបស់ប្រទេសក្នុងការទាញយកផលពីសក្តានុពល នៃឧស្សាហកម្មកម្មន្តសាលរបស់ខ្លួន ។ ការអង្កេតមួយពីកាលានុវត្តភាពផ្សេងៗនាបច្ចុប្បន្ន និងទៅអនាគត បានបង្ហាញថា វិស័យនេះផ្តល់ក្តីសង្ឃឹមច្រើន ។ ដោយឡែកកាលានុវត្តភាពមួយដែលបានអង្កេតឃើញ គឺ ទីតាំងជាយុទ្ធសាស្ត្ររបស់កម្ពុជា ។ ការកសាងផ្លូវដែកតភ្ជាប់ក្នុងតំបន់ នឹងបើកចំហទីផ្សារកាន់តែធំសំរាប់ការផ្លាស់ប្តូរជំនាញចំណេះដឹង និងផលិតផល ។ កាលានុវត្តភាពមួយទៀត ទាក់ទងនឹងការផ្លាស់ប្តូរនៅក្នុងទីផ្សារពលកម្ម ។ ឧទាហរណ៍ គេបានទស្សទាយថា នឹងមានពលករខាងកសិកម្មកាន់តែច្រើន ដែលចង់ចូលទៅបំរើការក្នុងឧស្សាហកម្មកម្មន្តសាលវិញ នៅពេលពួកគេបានរៀននូវជំនាញដ៏ចាំបាច់រួចហើយ ។ ស្ថានភាពនេះនឹងបង្កើនសំពាធឱ្យខំពង្រីកកម្មន្តសាលកម្ម ។

ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ មិនមែនជាបញ្ហាតែមួយដែលវិស័យកម្មន្តសាលត្រូវប្រឈមនោះទេ ។ វិបត្តិបានបង្ខំឱ្យមានការយកចិត្តទុកដាក់លើបញ្ហាមានយូរមកហើយមួយ គឺ កង្វះការធ្វើចំរុះកម្ម ។ ការពឹងផ្អែកខ្លាំងលើផ្នែកកាត់ដេរ បានធ្វើឱ្យវិស័យឧស្សាហកម្មមិនអាចបំបែកនិងពង្រាយហានិភ័យកើត ហើយក៏មិនអាចគេចផុតពី ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ។ គោលនយោបាយខាងឧស្សាហកម្មមួយដែលផ្អែកលើបទពិសោធន៍រៀនសូត្របានពីវិបត្តិ គឺ ការផ្តល់អាទិភាពលើការធ្វើចំរុះកម្ម ។ ដូចបានលើកឡើងរួចហើយ ផលិតកម្មម្ហូបអាហារ មានចំណែកត្រឹមតែ ១0% ប៉ុណ្ណោះនៅក្នុងផលិតកម្មឧស្សាហកម្ម ។ ផ្នែកនេះអាចកែលំអទៀតបាន ជាពិសេសឈរលើការពិតដែល ផលិតផលនាំចូលជាច្រើន ផលិតចេញពីវត្ថុធាតុដើមដែលកកើតឡើងនៅកម្ពុជា ។

ឧបសគ្គមួយទៀតចំពោះកំណើនកម្មន្តសាលកម្ម គឺ ស្ថានភាពអភិបាលកិច្ចខាងផ្លូវច្បាប់ដែលមានបញ្ហា ។ គេមិនគួរមើលស្រាលពីសារៈសំខាន់នៃការពង្រឹងអនុវត្តកិច្ចសន្យា សំរាប់វិនិយោគិន និងធនាគារឡើយ ។ ការបង្កើតតុលាការពាណិជ្ជកម្មឯករាជ្យមួយដែលមានចៅក្រមប្រកបដោយគុណភាពក៏សំខាន់ណាស់ដែរ ។

គេមិនអាចគេចផុតពីការចោទសួរថា តើដុល្លារូបនីយកម្មក៏រិតខ្ពស់នៅតែមានប្រយោជន៍សំរាប់ប្រទេសកម្ពុជា ឬយ៉ាងណានោះទេ ។ ផលចំណេញនិងគុណវិបត្តិនៃដុល្លារូបនីយកម្ម ត្រូវតែយកមកពិនិត្យឡើងវិញ ។ ផលចំណេញមួយ គឺ វិនិយោគិនបរទេសនិយមធ្វើជំនួញជាប្រាក់ដុល្លារ ចំណែកឯគុណវិបត្តិវិញ គឺ វាលុបបំបាត់លទ្ធភាពប្រើប្រាស់ការបញ្ចុះតំលៃរូបិយវត្ថុដើម្បីបង្កើនភាពប្រកួតប្រជែង ។

សកម្មភាពផ្សេងទៀតដែលអាចជំរុញការអភិវឌ្ឍកម្មន្តសាលកម្ម គឺ ការបង្កើនវិនិយោគលើការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជៀសវាងប្រើគ្រឿងលើកទឹកចិត្តខាងពន្ធដារ និង ការកាត់បន្ថយចំណាយក្រៅផ្លូវការលើវិនិយោគ ។ ការអង្កេតថ្មីៗមួយបានរកឃើញថា មានសហគ្រាសចំនួន ៥២% បានកំណត់អំពើពុករលួយជាកត្តារាំងស្ទះយ៉ាងធំសំរាប់វិនិយោគ ។ រឿងនេះក៏បានដាក់បញ្ចូលការងារដោះស្រាយអំពើពុករលួយទៅក្នុងរបៀបវារៈ ។

ឧស្សាហូបនីយកម្ម បានជួយសំរួលដល់ការអភិវឌ្ឍនៅប្រទេសជាច្រើន ។ នេះជាមាគ៌ាដែលបើកចំហសំរាប់កម្ពុជាដែរ ប៉ុន្តែការធ្វើដំណើរមិនមែនងាយស្រួលទេ ។ ដើម្បីសំរេចគោលដៅនេះ ត្រូវមានសកម្មភាពស៊ីចង្វាក់គ្នារវាងរដ្ឋាភិបាល នឹងដៃគូអភិវឌ្ឍន៍នានា ៕

## តើអ្នកបានដឹងទេថា

**... កម្ពុជា កំពុងស្ថិតក្នុងដំណើរការបង្កើត "ទំនប់វារីអគ្គិសនីទន្លេឆាងជាង" របស់ខ្លួនមួយ?** ទំនប់កំចាយក្នុងខេត្តកំពត ដែលប្រៀបដូច ទំនប់វារីអគ្គិសនីទន្លេឆាងជាងរបស់ចិន ដោយសារទំហំដ៏ធំ របស់វាក្នុងបរិបទកម្ពុជានោះ កំពុងតែសាងសង់ឡើង ។ គម្រោងវារីអគ្គិសនីជាច្រើនទៀតដែលជំរុញឡើងជាសំខាន់ដោយសារវិនិយោគរបស់ប្រទេសចិន កំពុងដំណើរការសាងសង់ ឬនឹងត្រូវសាងសង់ ។ គម្រោងទាំងនេះ រួមមានទាំង ទំនប់នានានៅជុំវិញតំបន់ភ្នំក្រវាញផង ។ គោលបំណងដែលប្រកាសចេញលើការអភិវឌ្ឍទំនប់វារីអគ្គិសនីទាំងនេះ គឺសមរម្យគួរឱ្យកោតសរសើរ ប៉ុន្តែក៏នៅតែមានមតិរិះគន់ពី កង្វះតម្លាភាពក្នុងកិច្ចចរចា និងការយល់ឃើញថាពុំមានការគិតគូរពីផលប៉ះពាល់នៃគម្រោងទៅលើបរិស្ថាន ។ នៅឆ្នាំ២០០៨ របាយការណ៍រួមគ្នាមួយរវាងអង្គការមិនមែនរដ្ឋាភិបាល International Rivers (ទន្លេអន្តរជាតិ) និង Rivers Coalition in Cambodia (សហព័ន្ធទន្លេនៅកម្ពុជា) បានអះអាងថា "ការអភិវឌ្ឍវារីអគ្គិសនីនៅកម្ពុជា បានធ្វើឡើងដោយមិនមានការពិគ្រោះយោបល់គ្រប់គ្រាន់ជាសាធារណៈ និងកង្វះជាទូទៅនូវតម្លាភាពក្នុងដំណើរការធ្វើសេចក្ដីសំរេច ។" ម្យ៉ាងទៀត រដ្ឋសភាក៏បានអនុម័ត ច្បាប់មួយដែលដាក់ឱ្យរដ្ឋាភិបាលទទួលខុសត្រូវលើការ ខាតបង់ផ្នែកហិរញ្ញវត្ថុដែលអាចកើតមានឡើង ចំពោះគម្រោងវារីអគ្គិសនីពីររបស់ចិន ក្នុងករណីមានអស្ថិរភាពនយោបាយ ។

*ប្រភព : អង្គការទន្លេអន្តរជាតិ និង សហព័ន្ធទន្លេនៅកម្ពុជា ២០០៨ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ២០០៩, IRIN ២០០៩*




របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨-០៩ ផ្ដល់ការវិភាគលំអិតលើផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារ និងបញ្ហាចោទខាងគោលនយោបាយ ការពិនិត្យជាលក្ខណៈមីក្រូពីផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារនៅកំរិតភូមិ ផ្ដល់លទ្ធផលរកឃើញមួយចំនួន ក្នុងការស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ស្ដីពីការដឹកនាំនៅថ្នាក់ភូមិ និងការពិនិត្យត្រួសៗពីផលប៉ះពាល់ដែលវិបត្តិហិរញ្ញវត្ថុសាកល អាចបង្កចំពោះតំបន់អាស៊ី ប្រទេសកម្ពុជា និងជាពិសេសចំពោះជនក្រីក្រ និងជនងាយរងគ្រោះ ។ របាយការណ៍ក៏ពិនិត្យផងដែរពីបញ្ហាផ្សេងៗ ទាក់ទិននឹងការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជា ទំនាក់ទំនងរវាងចំនួនម៉ោងធ្វើការ និងសុខភាពកុមារនៅតាមបណ្ដាសហគមន៍ធ្វើកសិកម្មនៅជនបទ ។